Samdech Moha Borvor Thipadei HUN MANET
Prime Minister of the Kingdom of Cambodia

Phnom Penh, 24 July 2025

H.E. Ambassador Asim Iftikhar Ahmad
Permanent Representative of Pakistan to the United Nations,
President of the Security Council for July 2025
New York

Your Excellency,

I am writing to bring to your urgent attention as well as that of the other members of the United Nations Security Council, the recent armed aggression against Cambodia by Thai military forces at the border between the Kingdom of Cambodia and the Kingdom of Thailand, as follows:

Since the early morning of 24 July 2025, Thai armed forces launched unprovoked, premeditated and deliberate attacks on Cambodian positions along the border areas, including Tamone Thom Temple, Ta Krabey Temple and Mom Bei, in the provinces of Preah Vihear and Oddar Meanchey.

Cambodia condemns in the strongest terms and expresses its profound indignation over the unprovoked and premeditated military aggression by the Kingdom of Thailand's armed forces. This military attack flagrantly violated the principle of non-aggression and peaceful resolution of disputes—both of which are fundamental principles of international law, including the fundamental principles enshrined in the Charter of the United Nations and the ASEAN Charter, prohibiting the threat or use of force against the territorial integrity of any State, as well as a total disregard of the spirit of good neighborliness that Cambodia has consistently strived to uphold up to now.

Facing this flagrant aggression, Cambodian troops had no option but to respond in self-defense in order to safeguard Cambodia's sovereignty and territorial integrity. Cambodia calls on Thailand to immediately cease all hostilities, withdraw its forces to its side of the border, and refrain from any further provocative actions that could escalate the situation.

Allow me to recall that border tensions and armed hostilities continue to persist between Cambodia and Thailand, despite the existence of the Franco-Siamese Convention of 1904 and Treaty of 1907, as well as the maps produced by the Commission of Delimitation of the boundary between Indo-China and Siam set up under these two international instruments, and the Memorandum of Understanding on the Survey and Demarcation of Land Boundary ( MOU-2000 ) in which both sides commit to jointly demarcate the land boundary between the two countries based on these legal documents.

As in earlier cases, the current border hostilities between the two countries stem from Thailand's insistence on claiming sovereignty over the border areas, using its unilaterally drawn map that lacks any legal basis, and contrarily to its commitment under the MOU-2000. As a pretext for the current armed aggression, Thailand also made baseless and unfounded allegations against Cambodia over the landmine explosion after Thai personnels deviated from the patrol routes previously coordinated between the two countries and created a new path through Cambodian territories, known to be officially documented mine-fields.

It is profoundly reprehensible that this act of aggression occurs while Cambodia is actively pursuing peaceful and impartial legal avenues to resolve outstanding border issues with Thailand through both bilateral and international mechanisms. As the international community is aware, the Royal Government of Cambodia has decided on 02 June 2025 to refer to the ICJ for adjudication on four disputed border areas - Mom Bei, Tamone Thom Temple, Tamone Touch Temple, and Ta Krabey Temple. This military escalation by Thailand takes place in spite of regional and international appeals for restraint and peaceful solutions and Cambodia's demonstrated commitment to dialogue, including our hosting of the Joint Boundary Commission ( JBC ) meeting in Phnom Penh on 14-15 June 2025.

Considering the recent extremely grave aggressions by Thailand, which have gravely threatened peace and stability in the region, I earnestly request you to convene an urgent meeting of the Security Council to stop Thailand's aggression. I would also highly appreciate it if you could circulate this letter to the members of the Security Council as a document of the Council.

Please accept, Excellency, the assurances of my highest consideration.

HUN MANET

*បកប្រែក្រៅផ្លូវការ*

**លិខិតរបស់សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០២៥**
**ផ្ញើជូន ឯកឧត្តម Asim Iftikhar Ahmad**
**ឯកអគ្គរដ្ឋទូតតំណាងអចិន្ត្រៃយ៍នៃប្រទេសប៉ាគីស្ថាន ប្រចាំអង្គការសហប្រជាជាតិ និងជាប្រធានប្ដូរវេននៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សម្រាប់ខែកក្កដា ឆ្នាំ២០២៥**

------------------------

ខ្ញុំសូមជម្រាបជូន ឯកឧត្តម ក៏ដូចជាសមាជិកដទៃទៀតនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិជ្រាបជាបន្ទាន់ អំពីការឈ្លានពានដោយអាវុធមកលើប្រទេសកម្ពុជានាពេលថ្មីៗនេះ ដោយកងកម្លាំងយោធាថៃ នៅតាមព្រំដែនកម្ពុជា-ថៃ ដូចតទៅ៖

ចាប់តាំងពីព្រឹកព្រលឹមថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ កងកម្លាំងប្រដាប់អាវុធថៃបានបើកការវាយប្រហារដោយមានការគិតទុកជាមុន និងចេតនាបង្កហេតុ មកលើទីតាំងរបស់កម្ពុជាតាមបណ្ដោយតំបន់ព្រំដែន រួមមានតំបន់ប្រាសាទតាមាន់ធំ ប្រាសាទតាក្របី តំបន់មុំបី ដែលស្ថិតក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។

កម្ពុជាថ្កោលទោសយ៉ាងម៉ឺងម៉ាត់បំផុត និងមានសេចក្ដីទោមនស្សយ៉ាងខ្លាំង ចំពោះការឈ្លានពាន ដោយកងកម្លាំងប្រដាប់អាវុធរបស់ព្រះរាជាណាចក្រថៃដែលមានការគិតទុកជាមុន និងចេតនាបង្កហេតុនេះ។ ការវាយប្រហារដោយយោធានេះ បានបំពានយ៉ាងជាក់ស្ដែងលើគោលការណ៍មិនឈ្លានពានគ្នា និងការដោះស្រាយវិវាទដោយសន្តិវិធី ដែលជាមូលដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិ និងគោលការណ៍ចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន ស្ដីពីការហាមមិនឱ្យធ្វើការគំរាមកំហែង ឬប្រើប្រាស់កម្លាំងឈ្លានពានបូរណភាពទឹកដីនៃរដ្ឋណាមួយ ក៏ដូចជាការមិនគោរពចំពោះស្មារតីអ្នកជិតខាងល្អ ដែលកម្ពុជាបានខិតខំប្រកាន់ខ្ជាប់រហូតមកដល់ពេលនេះ។

ប្រឈមមុខនឹងការឈ្លានពានដ៏ព្រហើននេះ កងទ័ពកម្ពុជាគ្មានជម្រើសអ្វីក្រៅពីធ្វើការវាយបកដើម្បីការពារខ្លួន ការពារអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា។ កម្ពុជាអំពាវនាវឱ្យថៃបញ្ឈប់រាល់ទង្វើអរិភាពជាបន្ទាន់ ដកកម្លាំងទៅខាងព្រំដែនរបស់ខ្លួន និងចៀសវាងសកម្មភាពញុះញង់បង្កហេតុដែលអាចធ្វើឱ្យស្ថានការណ៍កាន់តែតានតឹង។

ខ្ញុំសូមអនុញ្ញាតរំលឹកថា ភាពតានតឹងនៅតាមព្រំដែន និងអរិភាពប្រដាប់អាវុធនៅតែបន្តកើតមានរវាងកម្ពុជា និងថៃ បើទោះបីជាមានអនុសញ្ញាបារាំង-សៀមឆ្នាំ ១៩០៤ និងសន្ធិសញ្ញាឆ្នាំ ១៩០៧ ក៏ដូចជាផែនទីដែលផលិតដោយគណៈកម្មការព្រំដែនរវាងឥណ្ឌូចិន និងសៀម ដែលបង្កើតឡើងដោយអនុលោមតាមលិខិតុបករណ៍អន្តរជាតិទាំងពីរ និងអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីការវាស់

វែងនិងខណ្ឌសីមាព្រំដែនគោកឆ្នាំ ២០០០ (MOU-2000) ដែលតាមរយៈ MOU ភាគីទាំងពីរបាន ប្តេជ្ញារួមគ្នាបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរ ផ្អែកលើឯកសារច្បាប់ទាំងនេះ។

ដូចករណីមុនៗដែរ អរិភាពតាមព្រំដែនរវាងប្រទេសទាំងពីរនាពេលបច្ចុប្បន្ននេះ កើតចេញពីការដែលប្រទេសថៃទទូចទាមទារអធិបតេយ្យដែនដីនៅតំបន់ព្រំដែន ផ្អែកលើមូលដ្ឋាននៃផែនទីដែលថៃខ្លួនឯងបានគូសជាឯកតោភាគី គ្មានមូលដ្ឋានច្បាប់ និងផ្ទុយពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការគោរព MOU-2000។ ដើម្បីជាលេសសម្រាប់ការឈ្លានពានប្រដាប់វុធនាពេលបច្ចុប្បន្ន ប្រទេសថៃក៏បានធ្វើការចោទប្រកាន់ដោយគ្មានមូលដ្ឋានមកលើកម្ពុជាជុំវិញការផ្ទុះគ្រាប់មីន បន្ទាប់ពីទាហានថៃបានដើរល្បាតខុសផ្លូវដែលប្រទេសទាំងពីរបានសម្របសម្រួល និងព្រមព្រៀងគ្នាពីកន្លងមក ហើយថៃមទាំងបានបង្កើតផ្លូវថ្មីមួយឆ្លងកាត់ទឹកដីកម្ពុជា នៅក្នុងតំបន់ដែលមានការទទួលស្គាល់ និងត្រូវបានចុះបញ្ជីជាផ្លូវការថាជាចំការមីន។

ជាការគួរឲ្យសោកស្តាយដែលមានអំពើឈ្លានពាននេះកើតឡើង ខណៈកម្ពុជាកំពុងបន្តខិតខំយ៉ាងសកម្មដើរតាមផ្លូវច្បាប់ ដោយសន្តិវិធី និងមិនលម្អៀងដើម្បីដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ជាមួយថៃ តាមរយៈយន្តការទ្វេភាគី និងអន្តរជាតិ។ ដូចដែលសហគមន៍អន្តរជាតិបានដឹងហើយថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៥ ក្នុងការបញ្ជូនទៅសុំតុលាការយុត្តិធម៌អន្តរជាតិធ្វើការវិនិច្ឆ័យចំពោះតំបន់ជម្លោះចំនួន៤ គឺតំបន់មុំបី ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច និងប្រាសាទតាក្របី។ កំណើនភាពតានតឹងផ្នែកយោធានេះ ត្រូវបានបង្កឡើងដោយប្រទេសថៃ បើទោះបីជាមានការអំពាវនាវក្នុងតំបន់ និងអន្តរជាតិឱ្យមានការអត់ធ្មត់ និងដំណោះស្រាយដោយសន្តិវិធី និងការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការសន្ទនា រួមទាំងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោកកម្ពុជា-ថៃ (JBC) នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៤-១៥ ខែមិថុនា ឆ្នាំ ២០២៥ កន្លងទៅ។

យោងលើការឈ្លានពានយ៉ាងគឃ្លើនរបស់ថៃនាពេលថ្មីៗនេះ ដែលបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ ខ្ញុំសូមស្នើឱ្យ **ឯកឧត្តម** កោះប្រជុំក្រុមប្រឹក្សាសន្តិសុខជាបន្ទាន់ ដើម្បីបញ្ឈប់ការឈ្លានពានរបស់ថៃ។ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ប្រសិនបើ **ឯកឧត្តម** អាចផ្សព្វផ្សាយលិខិតនេះ ជូនដល់សមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានយ៉ាងជ្រាលជ្រៅអំពីខ្ញុំ៕

(ហត្ថលេខា)

**ហ៊ុន ម៉ាណែត**